**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
លេខៈ ០១៤ គ.ជ.ប.ស.ជ.ណ

# សេចក្តីជូនដំណឹង
# ស្តីពី
# ការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ អាណត្តិទី៤ ឆ្នាំ២០២៤

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត** (**គ.ជ.ប**) សូមជម្រាបជូនដំណឹងជាសាធារណៈ ដល់គណបក្សនយោបាយទាំងអស់ ដែលបានចុះបញ្ជីស្របតាមច្បាប់ស្តីពីគណបក្សនយោបាយ ហើយដែលមានបំណងសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សារាជធានី ក្រុមប្រឹក្សាខេត្ត ក្រុមប្រឹក្សាក្រុង ក្រុមប្រឹក្សាស្រុក ក្រុមប្រឹក្សាខណ្ឌ (ក្រុមប្រឹក្សា) អាណត្តិទី៤ ឆ្នាំ២០២៤ ដែលនឹងប្រព្រឹត្តទៅនៅ**ថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០២៤** ឱ្យបានជ្រាបថា ៖

## ១. ការដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ

- ការទទួលពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ មានរយៈពេល ៥ (ប្រាំ) ថ្ងៃ គឺ**ចាប់ផ្តើមពីថ្ងៃទី២ ខែមីនា ឆ្នាំ២០២៤ និងបញ្ចប់នៅថ្ងៃទី៦ ខែមីនា ឆ្នាំ២០២៤**។
- គណបក្សនយោបាយត្រូវដាក់ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ (ទ.១០០៨) ទៅ គធ.ខប រៀងរាល់ម៉ោងធ្វើការ ពេលព្រឹកចាប់ពីម៉ោង ៧:០០ (ប្រាំពីរ) ដល់ម៉ោង ១១:៣០ (ដប់មួយ សាមសិប) នាទី និងពេលរសៀលចាប់ពីម៉ោង ១៤:០០ (ដប់បួន) ដល់ម៉ោង ១៧:៣០ (ដប់ប្រាំពីរ សាមសិប) នាទី។
- ទ.១០០៨ មានផ្តល់ជូនដោយឥតគិតថ្លៃ នៅទីស្តីការ គ.ជ.ប ទីស្នាក់ការ គធ.ខប ឬអាចទាញយកពីគេហទំព័ររបស់ គ.ជ.ប www.nec.gov.kh។
- ពាក្យសុំត្រូវចុះហត្ថលេខាដោយប្រធានគណបក្សនយោបាយ ឬតំណាងដែលបានទទួលការផ្ទេរសិទ្ធិជាលាយលក្ខណ៍អក្សរពីប្រធានគណបក្សនយោបាយនោះ។ ការផ្ទេរសិទ្ធិនេះមិនអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្តឡើយ លើកលែងតែក្នុងលិខិតផ្ទេរសិទ្ធិនោះ មានខ្លឹមសារអនុញ្ញាតឱ្យផ្ទេរសិទ្ធិបន្ត។
- ពាក្យសុំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា ត្រូវភ្ជាប់មកជាមួយនូវ ឯកសារពាក់ព័ន្ធដូចមានក្នុងទម្រង់បែបបទ ទ.១០០៨។


វិថីរដ្ឋសភា សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
St., Ratsaphea Tonle Basac, Khan Chamkar Mon, Phnom Penh, Cambodia
ទូរស័ព្ទ : 023 235 271
អ៊ីមែល : info@nec.gov.kh

## ២. ការរៀបចំចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ភ្ជាប់មកជាមួយពាក្យសុំចុះបញ្ជី

- ការរៀបចំបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត និងបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៤ ឆ្នាំ២០២៤ មាន ២ (ពីរ) របៀបគឺ ៖
  - គណបក្សនយោបាយអាចរៀបចំបញ្ជីបេក្ខជនឈរឈ្មោះ ដោយដៃ
  - គណបក្សនយោបាយអាចរៀបចំបញ្ជីបេក្ខជនឈរឈ្មោះ តាមកម្មវិធី។
- គណបក្សនយោបាយដែលមានបំណងរៀបចំបញ្ជីបេក្ខជនឈរឈ្មោះតាមកម្មវិធីត្រូវដាក់ពាក្យស្នើសុំបង្កើតគណនីមក គ.ជ.ប ដោយត្រូវភ្ជាប់មកជាមួយនូវឯកសារ ដូចខាងក្រោម ៖
  - ពាក្យស្នើសុំបង្កើតគណនីគណបក្សនយោបាយ
  - លិខិតផ្ទេរសិទ្ធិគ្រប់គ្រងគណនីគណបក្សនយោបាយ (ប្រសិនបើមាន)
  - សេចក្តីចម្លងលិខិតបញ្ជាក់ការចុះបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ជាសេចក្តីចម្លងប្រកាសស្តីពីការចុះឈ្មោះក្នុងបញ្ជីគណបក្សនយោបាយនៅក្រសួងមហាផ្ទៃ ដែលមានបញ្ជាក់នីត្យានុកូលកម្មដោយអង្គភាពច្រកចេញចូលតែមួយនៃរដ្ឋបាលរាជធានី ខេត្ត ឬការិយាល័យច្រកចេញចូលតែមួយនៃរដ្ឋបាលក្រុង ស្រុក ខណ្ឌ
  - ឈ្មោះគណបក្សនយោបាយជាអក្សរពេញ ជាអក្សរកាត់ និងសញ្ញាសម្គាល់ (Logo) គណបក្សនយោបាយ (ជាពណ៌ធម្មជាតិ និងសខ្មៅ ដែលមានទំហំធំបំផុតត្រឹម ៥ MB)។
- ការទទួលពាក្យសុំបង្កើតគណនីប្រើប្រាស់ កម្មវិធីគ្រប់គ្រងការចុះបញ្ជីគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតនិងបញ្ជីបេក្ខជនឈរឈ្មោះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាអាណត្តិទី៤ ឆ្នាំ២០២៤ គឺ**ចាប់ផ្តើមពីថ្ងៃទី១ ខែកុម្ភៈ ឆ្នាំ២០២៤ និងបញ្ចប់ត្រឹមថ្ងៃទី២៧ ខែកុម្ភៈ ឆ្នាំ២០២៤**។
- កម្មវិធីរៀបចំបញ្ជីបេក្ខជនឈរឈ្មោះនេះត្រូវបិទដំណើរការ**នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២៤**។
- គណបក្សនយោបាយដែលបានរៀបចំបញ្ជីបេក្ខជនតាមកម្មវិធីរួចហើយ ត្រូវបោះពុម្ពចេញពីកម្មវិធីនូវឯកសារសម្រាប់ភ្ជាប់ជាមួយពាក្យសុំចុះបញ្ជី (ទ.១០០៨) ដូចខាងក្រោម ៖
  - បញ្ជីបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៤ តាមលំដាប់អាទិភាពពីខ្ពស់មកទាប តាមប្រភេទក្រុមប្រឹក្សានីមួយៗ
  - សេចក្តីបញ្ជាក់ពីការចុះឈ្មោះបោះឆ្នោតរបស់បេក្ខជនក្នុងបញ្ជីបោះឆ្នោតផ្លូវការ ដើម្បីយកទៅឱ្យអាជ្ញាធរឃុំ សង្កាត់ ធ្វើការបញ្ជាក់ **(មិនត្រូវកោស ឬលុប)**។
  - សេចក្តីសម្រេចស្តីពីការតែងតាំងបេក្ខជនឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា។

គ.ជ.ប សង្ឃឹមទុកជាមុនថា គ្រប់គណបក្សនយោបាយ និង គធ.ខប នឹងយកចិត្តទុកដាក់សហការល្អ ដើម្បីជំរុញឱ្យការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា អាណត្តិទី៤ ឆ្នាំ២០២៤ ប្រព្រឹត្តទៅប្រកបដោយជោគជ័យ ។

ថ្ងៃព្រហស្បតិ៍ ១៤រោច ខែបុស្ស ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

រាជធានីភ្នំពេញ ថ្ងៃទី ៨ ខែកុម្ភៈ ឆ្នាំ២០២៤

**ជ.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**ប្រធាន**

**ប្រាជ្ញ ចន្ទ**